# កិំឆន្ទជាតក

## (ពោលអំពីផលឧបោសថកន្លះថ្ងៃ)




*ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធឧបោសថកម្ម បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **កិំឆន្ទោ កិមធិប្បាយោ** *ដូច្នេះជាដើម ។*

*ថ្ងៃមួយ ព្រះសាស្តាត្រាស់សួរឧបាសកឧបាសិកាទាំងឡាយជាច្រើន ដែលជាអ្នករក្សាឧបោសថ មកដើម្បីស្តាប់ធម៌ អង្គុយក្នុងធម្មសភាថា ម្នាលឧបាសកឧបាសិកាទាំងឡាយ អ្នកទាំងឡាយជាអ្នកប្រកបដោយឧបោសថឬ ? កាលឧបាសកឧបាសិកាទាំងឡាយនោះទូលថា ពិតមែនហើយ ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ឧបោសថដែលអ្នកទាំងឡាយបានធ្វើដោយរក្សានេះ ល្អប្រពៃហើយ សូម្បីបោរាណជនទាំងឡាយបានទទួលយសដ៏ធំ ក៏ដោយផលនៃឧបោសថកម្មកន្លះថ្ងៃដែរ ។ កាលឧបាសកឧបាសិកាទាំងឡាយ ទូលសូមអារាធនាហើយ ព្រះសាស្តានាំអតីតនិទានមកថា*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ដោយធម៌ ក្នុងនគរពារាណសី ព្រះរាជានោះមានសទ្ធា ជាអ្នកមិនប្រមាទក្នុងទាន សីល និងឧបោសថកម្ម ។ ព្រះរាជា ញ៉ាំងជនដ៏សេសមានអាមាត្យទាំងឡាយជាដើម ឲ្យសមាទាននូវកុសលមានទានជាដើម ។ ចំណែកបុរោហិតរបស់ព្រះអង្គ ជាអ្នកប្រព្រឹត្តស៊ីសាច់ខ្នងរបស់អ្នកដទៃ ជាអ្នកស៊ីសំណូក ជាអ្នកវិនិច្ឆ័យក្តីកោង ។ ក្នុងថ្ងៃឧបោសថមួយ ព្រះរាជាត្រាស់ឲ្យហៅអាមាត្យទាំងឡាយមក ហើយទ្រង់ត្រាស់ថា អ្នកទាំងឡាយចូររក្សាឧបោសថ ។ បុរោហិតនោះមិនបានសមាទានឧបោសថឡើយ ។ គ្រានោះ កាលព្រះរាជាកំពុងសួរពួកអាមាត្យថា អ្នកទាំងឡាយរក្សាឧបោសថហើយឬ ? ទើបត្រាស់សួរបុរោហិតនោះដែលទទួលសំណូក និងកាត់ក្តីកោងក្នុងពេលថ្ងៃ ដែលមកកាន់ទីគាល់ថា លោកអាចារ្យរក្សាឧបោសថហើយឬ ។ បុរោហិតនោះធ្វើមុសាវាទថា ទូលព្រះបង្គំរក្សាហើយ រួចទើបចុះពីប្រាសាទ ។*

*លំដាប់នោះ អាមាត្យម្នាក់ចោទបុរោហិតនោះថា លោកមិនបានរក្សាឧបោសថមិនមែនឬ ។ បុរោហិតនិយាយកែថា ខ្ញុំបរិភោគអាហារតែក្នុងកាលប៉ុណ្ណោះ ពេលទៅដល់ផ្ទះ ខ្ពុរមាត់ហើយ អធិដ្ឋានឧបោសថ ខ្ញុំនឹងមិនបរិភោគអាហារក្នុងល្ងាចទេ នឹងរក្សាសីលអស់រាត្រីដោយអាការយ៉ាងនេះ ឧបោសថកម្មកន្លះថ្ងៃនឹងមានដល់ខ្ញុំ ។ អាមាត្យម្នាក់នោះពោលថា ល្អគ្រាន់ លោកអាចារ្យ ។ បុរោហិតនោះទៅដល់ផ្ទះហើយ ក៏បានធ្វើយ៉ាងនោះ ។ ថ្ងៃមួយ កាលបុរោហិតនោះ អង្គុយវិនិច្ឆ័យក្តីក្នុងសាលាវិនិច្ឆ័យ មានស្ត្រីអ្នកមានសីលម្នាក់មកស្តាប់ការកាត់ក្តី នាងមិនបានឱកាសដើម្បីនឹងទៅផ្ទះ ទើបគិតថា យើងនឹងមិនកន្លងនូវឧបោសថកម្មឡើយ ដូច្នេះហើយ កាលដែលវេលាចូលទៅកាន់ទីជិតផុតហើយ ក៏ប្រារព្ធដើម្បីនឹងខ្ពុរមាត់ ។ ក្នុងខណៈនោះ មានគេនាំចំណិតស្វាយទុំមកឲ្យព្រាហ្មណ៍បុរោហិត ។ បុរោហិតនោះដឹងភាពជាអ្នករក្សាឧបោសថរបស់ស្ត្រីនោះ ក៏ឲ្យដល់នាង ដោយពោលថា នាងចូរបរិភោគចំណិតស្វាយទុំនេះហើយ ចូររក្សាឧបោសថចុះ ។ ស្ត្រីនោះក៏បានធ្វើយ៉ាងនោះ ។ កុសលកម្មរបស់ព្រាហ្មណ៍បុរោហិតមានត្រឹមតែប៉ុណ្ណោះឯង ។*

ចំណេរកាលតមក បុរោហិតនោះធ្វើកាលកិរិយា បានទៅកើតលើអលង្កតសិរិសយនៈ ក្នុងវិមានមាស លើភូមិភាគដែលដល់ព្រមដោយសោភ័ណភាព ក្នុងព្រៃស្វាយដែលគួររីករាយ ដែលមានប្រមាណ ៣ យោជន៍ នៅនឹងច្រាំងកោសិកិគង្គានទី ក្នុងហិមវន្តប្រទេស ហាក់ដូចជា ទើបភ្ញាក់ពីដេក មានរូបដ៏ស្រស់ស្អាត មានទេវកញ្ញា ១៦០០០ ប្រដាប់ដែលដោយគ្រឿងអលង្ការជាបរិវារ ។ ទេវបុត្រនោះបានសោយសិរីសម្បត្តិនោះតែក្នុងពេលរាត្រីប៉ុណ្ណោះ ។ ពិតមែនហើយ ទេវបុត្រនោះបានសោយវិបាកដូចគ្នានឹងកម្ម ដែលខ្លួនបានធ្វើដោយភាពជាវេមានិកប្រេត ព្រោះហេតុនោះ កាលអរុណរះឡើង ទេវបុត្រចូលទៅកាន់អម្ពវ័ន ក្នុងខណៈដែលចូលទៅនោះឯង អត្តភាពជាទិព្វក៏អន្តរធានបាត់ទៅ អត្តភាពដែលមានប្រមាណប៉ុនដើមត្នោត កម្ពស់ ៨០ ហត្ថ កើតឡើង សរីរៈទាំងអស់ឆេះឡើង ហាក់ដូចជាដើមចារដែលមានផ្ការីកស្គុះស្គាយ ។ ក្នុងដៃទាំងពីរ ម្រាមដៃនីមួយៗ មានក្រចកធំប្រមាណប៉ុនចបកាប់អាធំ ។ ទេវបុត្រយកក្រចកនោះខ្វារហែកសាច់ខ្នងខ្លួនឯង មកបរិភោគ កាលដល់នូវទុក្ខទេវនា ទើបស្រែកយំខ្លាំងៗ សោយសេចក្តីទុក្ខយ៉ាងនេះ ។

កាលព្រះអាទិត្យអស្តង្គតទៅ សរីរៈនោះក៏អន្តរធានទៅ សរីរៈជាទិព្វបានកើតឡើង មានស្ត្រីរបាំជាទិព្វដែលប្រដាប់ដោយគ្រឿងអលង្ការ កាន់គ្រឿងតន្ត្រីផ្សេងៗ មកចោមរោម ។ ទេវបុត្រនោះ កាលនឹងសោយមហាសម្បត្តិ ក៏ឡើងកាន់ប្រាសាទជាទិព្វ ក្នុងអម្ពវ័ន ដែលជាទីគួររីករាយ ។ វេមានិកប្រេតនោះ បានអម្ពវ័នដែលមានទំហំ ៣ យោជន៍នេះ ដោយផលនៃការឲ្យផ្លែស្វាយដល់ស្ត្រីអ្នករក្សាឧបោសថ, ចំណែកការខ្វេះហែកសាច់ខ្នង មកបរិភោគនេះ ដោយផលនៃការទទួលសំណូក និងកាត់ក្តីកោង, ការបានសោយទិព្វសម្បត្តិក្នុងពេលរាត្រី និងមានស្ត្រីរបាំ ១៦០០០ ចោមរោមបម្រើនេះ ដោយផលនៃឧបោសថកន្លះថ្ងៃ ។

ក្នុងកាលនោះ ព្រះរាជាពារាណសីឃើញទោសក្នុងកាមទាំងឡាយ ហើយបួសជាឥសី សាងបណ្ណសាលា លើភូមិភាគជាទីរីករាយ នៅចំណែកខាងក្រោមទន្លេគង្គា ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយឧញ្ឆាចរិយា (ការត្រាច់បិណ្ឌបាតចិញ្ចឹមជីវិត) ។ ថ្ងៃមួយ ផ្លែស្វាយទុំប៉ុន

ក្អមអាធំ ដែលនៅក្នុងព្រៃស្វាយនោះ ធ្លាក់ចុះទន្លេគង្គា ហើយហូរអណ្តែតតាមខ្សែទឹក មកដល់ទីខាងមុខកំពង់ជាទីបរិភោគរបស់តាបសនោះ ។ តាបសកាលជម្រះមុខ បានឃើញស្វាយកំពុងអណ្តែតមកនៅកណ្តាលទន្លេហើយ ចុះទៅក្នុងទឹក កាន់យកស្វាយនោះ នាំមកអាស្រម រក្សាទុកក្នុងផ្ទះភ្លើង យកកាំបិតមកពុះ ហើយបរិភោគមួយចម្អែត ចំណែកដែលនៅសល់ យកស្លឹកចេកមកគ្របទុក បន្តបន្ទាប់មក តាបសឆាន់ផ្លែស្វាយនោះរាល់ៗ ថ្ងៃ រឿយៗ រហូតទាល់តែអស់ ។

កាលផ្លែស្វាយនោះអស់ហើយ តាបសមិនអាចនឹងបរិភោគផលាផលដទៃ ព្រោះជាប់ជំពាក់រសតណ្ហា ទើបគិតថា យើងនឹងបរិភោគផ្លែស្វាយទុំនោះ ដូច្នេះ ទើបទៅកាន់ច្រាំងទន្លេ កាលសម្លឹងមើលទន្លេ ធ្វើសេចក្តីសន្និដ្ឋានថា បើមិនបានផ្លែស្វាយ យើងនឹងមិនក្រោក យ៉ាងនេះហើយអង្គុយនៅទីនោះឯង ។ តាបសនោះ ជាអ្នកមិនមានអាហារក្នុងទីនោះ ស្ងួតស្ងប់អស់ ១ ថ្ងៃ ២ ថ្ងៃ ៣ ថ្ងៃ ៤ ថ្ងៃ ៥ ថ្ងៃ ៦ ថ្ងៃ រហូតរាងកាយរីងស្ងួត ហួតហែង ក្រៀមក្រោះ ដោយខ្យល់និងកម្តៅ អង្គុយសម្លឹងរកមើលផ្លែស្វាយប៉ុណ្ណោះ ។ លំដាប់នោះ ក្នុងថ្ងៃទី ៧ នទីទេវតាកាលពិចារណា បានដឹងហេតុនោះ ហើយគិតថា តាបសនេះ ជាអ្នកលុះក្នុងអំណាចតណ្ហា មិនបរិភោគអាហារអស់ ៧ ថ្ងៃ មកអង្គុយសម្លឹងមើលទន្លេគង្គា កាលដែលយើងមិនឲ្យផ្លែស្វាយទុំដល់តាបសនេះ រមែងមិនគួរ កាលតាបសនេះមិនបានផ្លែស្វាយ គេនឹងស្លាប់ ចឹងយើងនឹងឲ្យដល់គេ ដូច្នេះទើបមក ហើយឋិតនៅលើអាកាសខាងលើទន្លេគង្គា កាលចរចាមួយអន្ទើដោយតាបសនោះ ទើបពោលគាថាទី ១ ថា

កិំឆន្ទោ កិមធិប្បាយោ, ឯកោ សម្មសិ ឃម្មនិ;
កិំបត្ថយានោ កិំ ឯសំ, កេន អត្ថេន ព្រាហ្មណ។

បពិត្រព្រាហ្មណ៍ លោកពេញចិត្តនឹងអ្វី ប៉ុនប៉ងអ្វី ប្រាថ្នាអ្វី ស្វែងរកអ្វី ទើបអង្គុយម្នាក់ឯងក្នុងរដូវក្តៅ ដោយប្រយោជន៍អ្វី ។

*នាងទេពធីតាហៅតាបសនេះថា* **ព្រាហ្មណ៍** *ព្រោះលោកបួសហើយ អធិប្បាយថា ម្នាលព្រាហ្មណ៍ លោកប្រាថ្នាអ្វី គិតដល់អ្វី ចង់បានអ្វី ស្វែងរកអ្វី ត្រូវការអ្វី លោកទើបមកអង្គុយសម្លឹងមើលទន្លេគង្គាត្រង់ច្រាំងទន្លេនេះ ។*

*តាបសស្តាប់ពាក្យនោះហើយ ក៏ពោល ៩ គាថា ថា*

យថា មហា វារិធរោ, កុម្ភោ សុបរិណាហវា;
តថូបមំ អម្ពបក្កំ, វណ្ណគន្ធរសុត្តមំ។

*ក្អមដាក់នូវទឹកដ៏ធំ មានទ្រង់ទ្រាយស្អាតបាត មានឧបមាយ៉ាងណា ផ្លែស្វាយទុំដ៏ឧត្តមដោយពណ៌ និងក្លិន និងរស ក៏មានឧបមេយ្យយ៉ាងនោះ ។*

តំ វុយ្ហមានំ សោតេន, ទិស្វានាមលមជ្ឈិមេ;
បាណីភិ នំ គហេត្វាន, អគ្យាយតនមាហរិំ។

*ម្នាលនាងមានអវយៈត្រង់កណ្ដាល (ចង្កេះ) មិនមានមន្ទិល អាត្មាបានឃើញផ្លែស្វាយនោះ អណ្តែតតាមខ្សែទឹក ក៏ចាប់ផ្លែស្វាយនោះដោយដៃទាំងពីរ ហើយនាំយកទៅកាន់រោងបូជាភ្លើង ។*

តតោ កទលិបត្តេសុ, និក្ខិបិត្វា សយំ អហំ;
សត្ថេន នំ វិកប្បេត្វា, ខុប្បិបាសំ អហាសិ មេ។

*លំដាប់នោះ អាត្មាបានដាក់ផ្លែស្វាយលើស្លឹកចេកទាំងឡាយដោយខ្លួនឯង ចិតនូវផ្លែស្វាយនោះដោយកាំបិតហើយ (ឆាន់) ផ្លែស្វាយនោះ នាំចេញនូវសេចក្តីស្រេកឃ្លានរបស់អាត្មាបាន ។*

សោហំ អបេតទរថោ, ព្យន្តីភូតោ ទុក្ខក្ខមោ;
អស្សាទំ នាធិគច្ឆាមិ, ផលេស្វញ្ញេសុ កេសុចិ។

*អាត្មានោះប្រាសចាកសេចក្តីក្រវល់ក្រវាយ លុះផ្លែស្វាយអស់ហើយ ក៏អត់ទ្រាំបានដោយលំបាក មិនបានសេចក្តីត្រេកអរ ក្នុងផ្លែឈើទាំងឡាយឯទៀតណាមួយ ។*

សោសេត្វា ធូន មរណំ, តំ មមំ អាវហិស្សតិ;
អម្ពំ យស្ស ផលំ សាទុ, មធុរគ្គំ មនោរមំ;
យមុទ្ធរឹ វុយ្ហមានំ, ឧទធិស្មា មហណ្ណវេ។

*ផ្លែស្វាយនោះ នឹងនាំមកនូវសេចក្តីស្លាប់ ដល់អាត្មាដោយពិត ព្រោះរឹងស្គម ព្រោះផ្លែស្វាយមានរសឆ្ងាញ់មានរសផ្អែមលើសលប់ ជាទីពេញចិត្ត ។*

អក្ខាតំ តេ មយា សព្ពំ, យស្មា ឧបវសាមហំ;
រម្មំ បតិ និសិន្នោស្មិ, បុថុលោមាយុតា បុថុ។

*អាត្មាបានស្រង់ផ្លែស្វាយ ដែលកំពុងអណ្តែតក្នុងអន្លង់ដ៏ធំអំពីស្ទឹង អាត្មានៅ (ដោយសេចក្តីស្រេកឃ្លាន) ព្រោះហេតុណា ហេតុនោះទាំងអស់ អាត្មាបានប្រាប់ដល់នាង ។*

ត្វញ្ច ខោ មេវ អក្ខាហិ, អត្តានមបលាយិនិ;
កា វា ត្វមសិ កល្យាណិ, កិស្ស វា ត្វំ សុមជ្ឈិមេ។

*អាត្មាអង្គុយអាស្រ័យនូវស្ទឹងជាទីរីករាយ ស្ទឹងនេះ ធំទូលាយប្រកបដោយត្រី នាងកុំអាលរត់ទៅ ចូរប្រាប់ខ្លួននោះ ដល់អាត្មាសិន ។*

រុប្បបដ្ដបលិមដ្ឋីវ, ព្យគ្ឃីវ គិរិសានុជា;

យា សន្តិ នារិយោ ទេវេសុ, ទេវានំ បរិចារិកា។

*ម្នាលនាងកល្យាណី នាងជាអ្វី ម្នាលនាងមានអវយវៈត្រង់កណ្ដាល (ចង្កេះ) ដ៏ល្អ នាងមានរូបដូចកតម្បាររមាសដ៏រលីង (មានដំណើរ) ដូចជាកូនខ្លាដែលកើតក្នុងញកភ្នំ (មកក្នុងទីនេះ) ដើម្បីអ្វី ។*

យា ច មនុស្សលោកស្មឹ, រូបេនាន្វាគតិត្ថិយោ;
រូបេន តេ សទិសី នត្ថិ, ទេវេសុ គន្ធព្វមនុស្សលោកេ;
បុដ្ឋាសិ មេ ចារុបុព្វង្គិ, ព្រូហិ នាមញ្ច ពន្ធវេ។

*នាងនារីទាំងឡាយណា ជាអ្នកបម្រើពួកទេវតា ក្នុងទេវតាទាំងឡាយផង ស្រីទាំងឡាយណាប្រកបដោយរូប ក្នុងមនុស្សលោកផង ស្រីទាំងឡាយនោះ ប្រាកដស្មើដោយរូបនៃនាងមិនមាន ក្នុងទេវគន្ធព្វ និងមនុស្សលោកឡើយ ម្នាលនាងមានអវយវៈខាងដើម (ភ្លៅ) ដ៏ល្អ អាត្មាសួរហើយ ចូរប្រាប់នាម និងគោត្រផង ផៅពង្សទាំងឡាយផង ។*

*លំដាប់នោះ ទេវធីតា ក៏ពោល ៨ គាថាថា*

យំ ត្វំ បតិ និសិន្នាសិ, រម្មំ ព្រាហ្មណ កោសិកិំ;
សាហំ កុសលយាវុត្ថា, វរវារិវហោឃសា។

*បពិត្រព្រាហ្មណ៍ លោកគង់នៅអាស្រ័យស្ទឹងឈ្មោះកោសិកីជាទីរីករាយណា ខ្ញុំមានលំនៅត្រង់ខ្សែទឹកដ៏កាច មានអន្លង់ជាទីហូរនៅនៃទឹកដ៏ប្រសើរ អាស្រ័យនៅហើយ (ក្នុងស្ទឹងនោះ) ។*

នានាទុមគណាកិណ្ណា, ពហុកា គិរិកន្ទរា;
មមេវ បមុខា ហោន្តិ, អភិសន្ទន្តិ ចាវុសេ។

ព្រោះភ្នំដ៏ច្រើន កុះករដោយឈើផ្សេងៗ រមែងមានក្នុងទីចំពោះមុខខ្ញុំ រមែងហូរទៅ ក្នុងរដូវភ្លៀង ។

អថោ ពហ្វា វធតោទា, ធីលវាវិវហិន្ធរា;
ពហុកា ជាគវិត្តោទា, អភិសន្ទន្តិ វារិជា។

ម្យ៉ាងទៀត ស្ទឹងដ៏ច្រើន មានទឹកហូរចេញអំពីព្រៃ ទ្រទ្រង់នូវគំនរទឹកដ៏ខៀវ ស្ទឹងដ៏ច្រើន មានរូបភាពដូចជានាគ រមែងញ៉ាំងខ្ញុំឲ្យពេញដោយទឹក ។

តា អម្ពជម្ពុលពុជា, ធីថា តាលា ចុទុម្ពរា;
ពហ្វាធិ ផលជាតាធិ, អាវហាន្តិ អភិណ្ហសោ។

ដើមស្វាយ ដើមព្រីង ដើមខ្នុរសម្ល ដើមក្តុម្ព ដើមត្នោតនិងដើមល្វា ផលជាតទាំងឡាយដ៏ច្រើន រមែងចូលទៅកាន់ស្ទឹងទាំងនោះរឿយៗ។

យំ កិញ្ចិ ឧភតោ តីរេ, ផលំ បតតិ អម្ពុធិ;
អសំសយំ តំ សោតស្ស, ផលំ ហោតិ វសានុគំ។

ផ្លែឈើណាមួយ នៅក្បែរមាត់ច្រាំងទាំងពីរ រមែងជ្រុះទៅក្នុងទឹក ផ្លែឈើនោះ រសាត់ទៅតាមអំណាចខ្សែទឹកដោយឥតសង្ស័យ ។

ឯតទញ្ញាយ មេធាវី, បុថុបញ្ញ សុណោហិ មេ;
មា រោចយ មភិសង្គំ, បដិសេធ ជជាធិប។

បពិត្រលោកជាអ្នកប្រាជ្ញ មានប្រាជ្ញាច្រើន លោកជ្រាបហេតុនុ៎ះហើយ សូមស្តាប់ ពាក្យខ្ញុំចុះ បពិត្រព្រះជនាធិបតី សូមលោកកុំពេញចិត្តឡើយ ចូរបដិសេធ នូវការជាប់ជំពាក់ដោយតណ្ហា ។

ន ភហំ វឌ្ឍរិ មញ្ញេ, យំ ត្វំ រដ្ឋាភិវឌ្ឍន;
អាចេយ្យមានោ រាជិសិ, មរណំ អភិកង្ខសិ។

*បពិត្រព្រះរាជិសី អ្នកញុំាំងដែនឲ្យចម្រើន លោកកំពុងចម្រើន ( ដោយសាច់និងឈាម) ប្រាថ្នាសេចក្ដីស្លាប់ ដោយហេតុណា ខ្ញុំពុំសំគាល់នូវលោកថា ជាអ្នកចម្រើនដោយប្រាថ្នា ដោយហេតុនោះទេ ។*

តស្ស ជានន្តិ បិតរោ, គន្ធព្វា ច សទេវកា;
យេ ចាបិ ឥសយោ លោកេ, សញ្ញតត្តា តបស្សិនោ;
អសំសយំ តេបិ ជានន្តិ, បដ្ឋភូតា យសស្សិនោ។

*បិតាទាំងឡាយ (ព្រហ្ម) និងគន្ធព្វព្រមទាំងទេវតា រមែងដឹងនូវភាពនៃបុគ្គលនោះថា ជាអ្នកលុះក្នុងអំណាចនៃតណ្ហា ម្យ៉ាងទៀត ឥសីទាំងឡាយណាក្នុងលោក ជាអ្នកមានចិត្តសង្រួមហើយ មានតបៈ ឥសីទាំងឡាយនោះ រមែងដឹងឥតសង្ស័យ ( សូម្បី) ពួកអ្នកមានយស ជាអ្នកបម្រើ ( ឥសីទាំងនោះក៏ដឹងការនោះតៗ គ្នាទៀត) ។*

*កាលនទីទេវធីតានឹងឲ្យតាបសនោះ កើតសេចក្ដីសង្វេគទើបពោលយ៉ាងនេះថា ព្រហ្មដែលដល់ការរាប់ថាជាបិតា គន្ធព្វព្រមទាំងកាមាវចរទេវតា មួយអន្លើដោយព្រហ្មនោះ និងពួកឥសីដែលមានចក្ខុទិព្វ រមែងដឹងបុគ្គលដែលធ្លាក់ចុះក្នុងអំណាចនៃតណ្ហា ដោយឥតសង្ស័យ ។ តែការដែលអ្នកមានឫទ្ធិទាំងនោះដឹងថា តាបសឯណោះជាបុគ្គលធ្លាក់ចុះ ក្នុងអំណាចនៃតណ្ហា មិនជាអស្ចារ្យទេ ។ ចំណែកអ្នកបម្រើ របស់ឥសីដែលតាំងសេចក្ដីព្យាយាម ជាអ្នកមានយស បានដឹងព្រោះស្ដាប់ពាក្យរបស់ជនទាំងនោះនិយាយគ្នាម្ដងទៀត ។ ឈ្មោះថា អាថ៌កំបាំងរបស់អ្នកធ្វើបាបកម្ម រមែងមិនមាន ។*

*បន្ទាប់ពីនោះមក តាបសក៏ពោល ៤ គាថាថា*

ឯវំ វិទិត្វា វិទូ សព្ពធម្មំ, វិទ្ធំសនំ ចវនំ ជីវិតស្ស;
ន ចីយតី តស្ស នរស្ស ចាបំ, សចេ ន ចេតេតិ វធាយ តស្ស។

*បើ ( នរជនណា ) មិនគិតសម្លាប់បុគ្គលនោះទេ បាបក៏មិនចម្រើនដល់នរជននោះ ដែលដឹងច្បាស់នូវធម៌ទាំងពួង របស់អ្នកប្រាជ្ញ យ៉ាងនេះផង ដឹងនូវការបែកធ្លាយនិងច្យុតិនៃជីវិតផង ។*

ឥសិបូគសមញ្ញាតេ, ឯវំ លោក្យា វិទិតា សតិ;
អនរិយបរិសម្ភាសេ, ចាបកម្មំ ជិគីសសិ។

*ម្នាលនាងជាធំ ដែលពួកឥសីដឹងច្បាស់ហើយ ប្រយោជន៍នៃសត្វលោក នាងដឹងច្បាស់ហើយយ៉ាងនេះ នាងឈ្មោះថាស្វែងរកនូវបាបកម្ម ( ចំពោះខ្លួន ) ព្រោះប្រទេចពាក្យមិនប្រសើរ ។*

សចេ អហំ មរិស្សាមិ, តីរេ តេ បុថុសុស្សោណិ;
អសំសយំ តំ អសិលោកោ, មយិ បេតេ អាគមិស្សតិ។

*ម្នាលនាងទេវធីតាមានត្រគាកសាយល្អ បើយើងស្លាប់លើត្រើយរបស់នាង កាលបើយើងស្លាប់ហើយ តំណិះដំណៀលនឹងបានមកនាងឯង ឥតសង្ស័យឡើយ ។*

តស្មា ហិ ចាបកំ កម្មំ, រក្ខស្សេវ សុមជ្ឈិមេ;
មា តំ សព្ពោ ជនោ បច្ឆា, បក្កុដ្ឋាយិ មយិ មតេ។

*ម្នាលនាងមានអវយវៈ ត្រង់កណ្តាលដ៏ល្អ ព្រោះហេតុនោះ នាងឯងចូររក្សានូវកម្ម អាក្រក់ កាលបើយើងស្លាប់ហើយ កុំឲ្យជនទាំងអស់ជេរប្រទេចនាង ក្នុងកាលជាខាងក្រោយ ឡើយ ។*

*ទេពធីតាស្តាប់ពាក្យនោះហើយ ទើបពោល ៥ គាថាថា*

អញ្ញាតមេតំ អវិសយ្ហសាហិ, អត្តាឧមម្ពញ្ញា ឧទាមិ តេ តំ,
យោ ទុព្ពជេ កាមគុណេ បហាយ, សន្តិញ្ចា ធម្មញ្ចា អធិដ្ឋិតោសិ។

*ហេតុនេះ ខ្ញុំម្ចាស់ដឹងច្បាស់ហើយ ធម្មតាស្តេចនេះ មិនងាយអត់ទ្រាំបានទេ ណ្ហើយចុះ ខ្ញុំម្ចាស់នឹងប្រគេននូវខ្លួនខ្ញុំម្ចាស់ផង ប្រគេននូវស្វាយនោះផង ដល់លោកម្ចាស់ ត្បិតលោក ម្ចាស់បានលះបង់នូវកាមគុណទាំងឡាយ ដែលគេលះបង់បានដោយក្រ ហើយបានអធិដ្ឋាន នូវសីល ជាគ្រឿងស្ងប់រម្ងាប់ផង នូវសុចរិតធម៌ផង ។*

យោ ហិត្វា បុព្ពសញ្ញោគំ, បច្ឆាសំយោជនេ ឋិតោ;
អធម្មញ្ចេវ ចរតិ, បាបញ្ចស្ស បវឌ្ឍតិ។

*បុគ្គលណា លះបង់នូវចំណងខាងដើម ហើយឋិតនៅក្នុងចំណងខាងចុងផង ប្រព្រឹត្ត នូវអធម៌ផង បាបតែងចម្រើនឡើងដល់បុគ្គលនោះ ។*

ឯហិ តំ បាបយិស្សាមិ, កាមំ អប្បោស្សុកោ ភវ;
ឧបនយាមិ សីតស្មិំ, វិហារាហិ អនុស្សុកោ។

*សូមលោកម្ចាស់មកចុះ ខ្ញុំម្ចាស់នឹងនាំលោកម្ចាស់ទៅឲ្យដល់ព្រៃស្វាយនោះ សូម លោកម្ចាស់មានសេចក្តីខ្វល់ខ្វាយតិចដោយពិតចុះ ខ្ញុំម្ចាស់នឹងនាំទៅដាក់ក្នុងព្រៃស្វាយដ៏ត្រជាក់នោះ សូមលោកម្ចាស់គង់នៅកុំមានសេចក្តីខ្វល់ខ្វាយ ។*

តំ បុប្ផរសមត្តេកិ, វក្កង្គេហិ អរិន្ទម;
កោញ្ចា មយូរា ទិវិយា, កោលដ្ឋិមធុសាឡិកា;
កូជិតា ហំសបូគេហិ, កោកិលេត្ថ បពោធរេ។

*បពិត្រអរិន្ទមៈ ព្រៃស្វាយនោះ ពួកសត្វបក្សីមានកក្កូក់ ស្រវឹងដោយរសនៃផ្កាឈើ ស្រែកបន្ទឺឡើងហើយ ពួកក្រៀល ពួកក្ងោក ជាទិព្វ ពួកសត្វស្វាបឈ្មោះកោលដ្ឋិ និងឈ្មោះមធុសាឡិកៈ យំជាមួយនឹងពួកហង្ស ពួកតាវៅ ដែលនៅក្នុងព្រៃស្វាយនោះ ក៏ញាំងពួកសត្វទាំងនោះឲ្យភ្ញាក់ឡើងហើយ ។*

អម្ពេត្ថ វិប្បសាខគ្គា, បលាលខលសន្និភា;
កោសម្ពសលឡា ធីថា, បក្កតាលវិលម្ពិនោ។

*ដើមស្វាយទាំងឡាយក្នុងព្រៃនោះ មានចុងមែកដាបចុះ (ព្រោះទម្ងន់ផ្លែ) ប្រាកដស្មើដោយទីលានដែលពេញដោយកណ្តាប់ស្រូវ ដើមដកគាំ ស្រល់ និងកទម្ពទាំងឡាយ មានចង្កោមផ្លែសំយុងចុះ ដូចធ្លាយផ្លែត្នោតទុំ ។*

*លោកពោលអធិប្បាយថា នៃតាបសដ៏ចម្រើន បុគ្គលណាលះបង់រាជសម្បត្តិដ៏ធំហើយមកជាប់ជំពាក់នឹងរសតណ្ហា ត្រឹមតែផ្លែស្វាយទុំ មិននឹកនាដល់ខ្យល់និងកម្តៅ អណ្តែតរីងរៃនៅនឹងច្រាំងទន្លេ បុគ្គលនោះកាលឆ្លងមហាសមុទ្រ ប្រៀបដូចបុគ្គលដែលអណ្តែតនៅទីបំផុតនៃច្រាំង ។ បុគ្គលណាជាអ្នកលុះក្នុងអំណាចនៃតណ្ហា ប្រព្រឹត្តអធម៌ កាលធ្វើដោយ*

អំណាចនៃតណ្ហា បាបរមែងចម្រើនដល់បុគ្គលនោះ ។ ទេពធីតាកាលតិះដៀលតាបស ទើបពោលដូច្នេះ ។

កាលទេវធីតាពណ៌នាហើយ នាងក៏នាំតាបសទៅដាក់ក្នុងព្រៃស្វាយនោះ ហើយពោលថា លោកកាលបរិភោគផ្លែស្វាយក្នុងអម្ពវ័ននេះហើយ ចូរញ៉ាំងតណ្ហារបស់ខ្លួនឲ្យពេញចុះ ថាដូច្នេះហើយ ទើបចៀសចេញទៅ ។ តាបសបរិភោគផ្លែស្វាយ និងញ៉ាំងតណ្ហាឲ្យពេញហើយ ក៏សម្រាក កាលប្រព្រឹត្តនៅក្នុងអម្ពវ័នក៏បានឃើញវេមានិកប្រេតដែលកំពុងសោយទុក្ខ តែលោកមិនអាចនឹងពោលយ៉ាងណាឡើយ ។ ក្នុងកាលព្រះសូរិយាអស្តង្គតទៅ តាបសឃើញប្រេតនោះសោយទិព្វសម្បត្តិ ដែលមានស្ត្រីរបាំជាបរិវារ ហើយទើបពោល ៣ គាថាថា

មាលី តិរិដី កាយូរី, អង្គទី ចន្ទនុស្សទោ;
រត្តឹ ត្វំ បរិចារេសិ, ទិវា វេទេសិ វេទនំ។

អ្នកទ្រទ្រង់នូវផ្កាកម្រង ទ្រទ្រង់នូវឈ្នួត ប្រដាប់ដោយគ្រឿងអាភរណៈ ពាក់នូវពាហុរត្ន (កងកន់) ប្រស់ព្រំដោយខ្លឹមចន្ទន៍ ឲ្យគេបម្រើក្នុងវេលាយប់ សោយនូវទុក្ខវេទនាក្នុងវេលាថ្ងៃ ។

សោឡសិត្ថិសហស្សានិ, យា តេមា បរិចារិកា;
ឯវំ មហានុភាវោសិ, អព្ភុតោ លោមហំសនោ។

ស្រីទាំងឡាយ ១៦០០០ នេះ ជាស្រីបម្រើរបស់អ្នក អ្នកជាបុគ្គលមានអានុភាពច្រើនយ៉ាងនេះ អស្ចារ្យ គួរឲ្យព្រឺរោម ។

កិំ កម្មមករី បុព្វេ, ចាបំ អត្តទុខាវហំ;

**យំ ករិត្វា មនុស្សេសុ, បិដ្ឋិមំសានិ ខាទសិ។**

*ក្នុងកាលមុន អ្នកបានធ្វើអំពើបាប នាំមកនូវទុក្ខដល់ខ្លួនដូចម្តេច ដែលអ្នកធ្វើក្នុងមនុស្សលោក បានជាស៊ីនូវសាច់ខ្នង (របស់ខ្លួន) ។*

*ប្រេតចាំតាបសនោះបាន ហើយពោលថា ព្រះអង្គមិនស្គាល់ខ្ញុំទេឬ ខ្ញុំជាបុរោហិតរបស់ព្រះអង្គ ខ្ញុំបានសោយសេចក្តីសុខក្នុងវេលាយប់ ព្រោះផលនៃឧបោសថកន្លះថ្ងៃដែលខ្ញុំបានធ្វើដោយអាស្រ័យព្រះអង្គ បានសោយសេចក្តីទុក្ខក្នុងពេលថ្ងៃ ដោយផលនៃបាបជាប្រក្រតីរបស់ខ្ញុំ ។ ខ្ញុំដែលព្រះអង្គតាំងទុកក្នុងតំណែងជាអ្នកវិនិច្ឆ័យ បានធ្វើការកាត់ក្តីកោងទទួលសំណូក ជាអ្នកស៊ីសាច់ខ្នងអ្នកដទៃ ព្រោះផលនៃកម្មដែលបានធ្វើទុកនោះ ខ្ញុំទើបសោយសេចក្តីទុក្ខនេះក្នុងពេលថ្ងៃ ដូច្នេះហើយ ទើបពោលគាថា ២ ថា*

**អជ្ឈេនានិ បដិគ្គយ្ហ, កាមេសុ គធិតោ អហំ;**
**អចរឹ ទីឃមទ្ធានំ, បរេសំ អហិតាយហំ។**

*ខ្ញុំបានរៀននូវវេទទាំងឡាយ ហើយជាប់ជំពាក់ក្នុងកាមទាំងឡាយ បានប្រព្រឹត្តមិនជាប្រយោជន៍ដល់ជនដទៃ អស់កាលដ៏យូរអង្វែង ។*

**យោ បិដ្ឋិមំសិកោ ហោតិ, ឯវំ ឧក្កច្ច ខាទតិ;**
**យថាហំ អជ្ជ ខាទាមិ, បិដ្ឋិមំសានិ អត្តនោ។**

*បុគ្គលណា ជាអ្នកស៊ីនូវសាច់ខ្នង (ញុះញង់គេ) បុគ្គលនោះ ក៏ខ្វារស៊ីនូវសាច់ខ្នងរបស់ខ្លួន ដូចខ្ញុំស៊ីក្នុងថ្ងៃនេះដែរ ។*

*វេមានិកប្រេតបានពោលពាក្យនេះហើយ ក៏សួរតាបសថា លោកម្ចាស់មកទីនេះបានដោយប្រការដូចម្តេច ។ តាបសពោលរឿងរ៉ាវទាំងអស់ ដោយពិស្តារ ។ ប្រេតសួរទៀតថា*

បពិត្រលោកម្ចាស់ដ៏ចម្រើន ឥឡូវនេះ លោកនឹងនៅក្នុងទីនេះ ឬនឹងទៅវិញ ? តាបសពោលថា យើងមិននៅទេ យើងនឹងទៅកាន់អាស្រមប៉ុណ្ណោះ ។ ប្រេតពោលថា បពិត្រលោកម្ចាស់ប្រពៃណាស់ ខ្ញុំនឹងទំនុកបម្រុងលោកម្ចាស់ដោយផ្លែស្វាយទុំជាប្រចាំ ថាហើយ ក៏នាំយកតាបសទៅដាក់ចុះក្នុងអាស្រម ដោយអានុភាពរបស់ខ្លួន រួចឲ្យតាបសកាន់យកបដិញ្ញាថា សូមលោកម្ចាស់កុំអផ្សុកអី ចូរនៅក្នុងទីនេះចុះ ដូច្នេះហើយ ទើបទៅ ។ ចាប់ពីពេលនោះមក ប្រេតនោះក៏បានទំនុកបម្រុងតាបសដោយផ្លែស្វាយទុំជាប់ជានិច្ច ។ តាបសកាលបានបរិភោគផ្លែស្វាយនោះ ហើយធ្វើកសិណបរិកម្ម ញាំងឈាននិងអភិញ្ញាឲ្យកើតឡើង ជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តាបាននាំព្រះធម្មទេសនានេះ ដល់ឧបាសកឧបាសិកាទាំងឡាយហើយ ទ្រង់ប្រកាសសច្ចធម៌ និងប្រជុំជាតក ក្នុងកាលជាទីបញ្ចប់នៃសច្ចធម៌ បុគ្គលខ្លះបានសម្រេចជាព្រះសោតាបន្ន បុគ្គលខ្លះបានជាព្រះសកទាគាមី បុគ្គលខ្លះបានជាព្រះអនាគាមី ។

**តទា ទេវធីតា ឧប្បលវណ្ណា អហោសិ** ទេពធីតាក្នុងកាលនោះ បានមកជាឧប្បលវណ្ណា

**តាបសោ បន អហមេវ អហោសឹ** ចំណែកតាបស គឺ តថាគតនេះឯង ។

កឹឆន្ទជាតក ចប់ ៕

( ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក តឹសនិបាត បិដកលេខ ៦០ ទំព័រ ១៤៩)

ថ្ងៃសៅរ៍ ១២ កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០

ថ្ងៃទី ២៦ ខែ ឧសភា ព.ស. ២៥៦២ គ.ស.២០១៨

ដោយស.ជ.វ.ថ.